គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើន
ផលិតភាព ជុំវិញតំបន់ទន្លេសាប
TSTD (ADB TA 7305-CAM)

# បច្ចេកទេសចិញ្ចឹមបំប៉នមាន់សាច់



### ទីតាំងទំនាក់ទំនងទិញកូនមាន់ស្រុកចិញ្ចឹម

**ខេត្ត កំពង់ចាម**

- ក្រុងសួង: ចេវ ស្រីម៉ៅ 097 613 0297
- ស្រុកជើងព្រៃ: ហូរ ប៊ុនថេង 089 468 277
- ស្រុកកំពង់សៀម: ហុក ឡុងស្រេង 012 783 104

**ខេត្ត បន្ទាយមានជ័យ**

- ស្រុកមង្គលបុរី: ផាន ភាព 092 933 883
- ស្រុកអូរជ្រៅ: ហេង គឹមហ៊ុន 088 444 7994
- ស្រុកព្រះនេត្រព្រះ: ភ្លឹង សុណ្ណដា 092 829 021

**ខេត្ត សៀមរាប**

- ស្រុកសូទ្រនិគម: លី ស៊ីណាត 012 483 440

ឧបត្ថម្ភថវិកាដោយ:
រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និង ធនាគារអភិវឌ្ឍន៍អាស៊ី

ខែ មេសា ឆ្នាំ ២០១៣

## សេចក្តីផ្តើម

ការចិញ្ចឹមមាន់ស្រុក ផ្តល់ប្រភពចំណូលបន្ថែមជាប្រចាំដល់គ្រួសារ ដោយចំណាយពេលទំនេរ និង ធនធានមួយចំនួនប៉ុណ្ណោះ។ កូនមាន់ស្រុកនៅកន្លែងភ្ញាស់នេះ ទទួលបានការគ្រប់គ្រងតាមបច្ចេកទេសត្រឹមត្រូវ ជួយមិនឲ្យមាន់ឈឺ និងងាប់ដោយសារជម្ងឺកាចសាហាវនានា។ ពូជមាន់ក្នុងស្រុកមានការពេញនិយមពីអ្នកហូប មានតម្រូវការទីផ្សារខ្ពស់ និងងាយស្រួលលក់ (មានតម្លៃថ្លៃ) ។ តាមរយៈបច្ចេកទេសចិញ្ចឹមនេះ កូនមាន់ស្រុក ១ក្បាល (អាយុ ២១ ថ្ងៃ) ចិញ្ចឹមក្នុងរយៈពេលតែ ៨៥ថ្ងៃ អាចទទួលបានទម្ងន់ជាមធ្យម ១,២គីឡូក្រាម។ តាមបទពិសោធន៍កន្លងមក កសិករចិញ្ចឹមអាចទទួលបានប្រាក់ចំណេញសុទ្ធ ក្នុង ១គីឡូក្រាមមាន់រស់ ជាមធ្យមពី ៦០០០ ទៅ ៧០០០រៀល ។ ប្រាក់ចំណូលសរុប នឹងកើនឡើង បើកសិករចិញ្ចឹមកូនមាន់ស្រុកបំប៉នយកសាច់កាន់តែច្រើន។

### គុណសម្បត្តិកូនមាន់ស្រុកភ្ញាស់នៅកសិដ្ឋានសម្រាប់យកទៅចិញ្ចឹមបំប៉ន

- កូនមាន់មានសុខភាពល្អ និងលូតលាស់លឿន
- មានអាយុពី ២១ ដល់ ៣០ថ្ងៃ និង មានទម្ងន់សមស្របសម្រាប់ចិញ្ចឹម
- ចិញ្ចឹមមិនងាយឈឺ ដោយបានចាក់វ៉ាក់សាំងការពារជម្ងឺ ២-៣មុខ រួចជាស្រេច (ជម្ងឺញ៉ូវកាស កំប៉ូរ៉ូ និង អុត) ។ អ្នកចិញ្ចឹមសាច់ត្រូវចាក់បន្ថែម វ៉ាក់សាំងជម្ងឺអាសន្នរោគនៅពេលមាន់អាយុបាន ២ខែ។

## តើចិញ្ចឹមមាន់សាច់ដូចម្តេច ឲ្យទទួលបានជោគជ័យ ?

### ១. ការសង់ទ្រុងគំរូចិញ្ចឹមបំប៉នកូនមាន់សាច់

- ទ្រុងបណ្តោយ ៦ម និងទទឹង ៣ម ចែកជា ២បន្ទប់
- ជើងរៀងទ្រុងមានកំពស់ ១,៧ម និងសសរកណ្តាលកំពស់ ៣,២ម
- បាំងសំណាញ់ចេញក្រៅពី ៣ទៅ ៤ម និងចែកជាបន្ទប់ៗសម្រាប់មាន់ដើរខាងក្រៅ និងហាលថ្ងៃ




- ធ្វើធ្នើរមាន់ដេក កំពស់ពីដី ០,៧ម និងបន្ទាធ្នើរ ០,៧ម
- ផ្ទៃដី ១ម$^{២}$ (កន្លែងដេក) ដាក់មាន់បានពី ៧ ទៅ ៨ក្បាល



### ២. ស្នូកចំណី និងស្នូកទឹកមាន់

ស្នូកចំណី អាចច្នៃពីប៊ីដុង ឬកានជ័រតូចធំ។



